$$=\pi\int_0^1 xdx-\pi\int_0^1 x^4dx$$

តាម ម៉ាស៊ីនគិតលេខ *fx* 991 ES

ចូលការគណនាទូទៅ MODE 1

កំណត់ចេញលទ្ធផលជារ៉ាដ្យង់ SHIFT MODE 4

បញ្ចូលទិន្នន័យ SHIFT ×10ˣ ∫ ALPHA ) ▶ 0 ▶ 1 ▶ −
SHIFT ×10ˣ ∫ ALPHA ) xⁿ 4 ▶ ▶ 0
▶ 1 = $\frac{3\pi}{10}$




គេបាន $V=\frac{3\pi}{10}$ ឯកតាមាឌ

**លំហាត់គំរូទី ៤** : គណនាមាឌសូលីតបរិវត្តបានពីរង្វិលជុំវិញអ័ក្សអាប់ស៊ីសនៃផ្ទៃដែលខណ្ឌដោយក្រាបតាងអនុគមន៍ $f(x)=x^2+1$ និង $g(x)=-x+3$ ត្រូវនឹង $0\le x\le 1$ ។

## ចម្លើយ

ក្រាបតាងអនុគមន៍ $f(x)=x^2+1$ ជាប៉ារ៉ាបូលមានកំពូល $(0\,,1)$ កាត់តាមចំណុច

| | | |
|---|---|---|
| $x$ | $-2$ | $1$ |
| $y$ | $5$ | $2$ |




ក្រាបតាងអនុគមន៍ $g(x)=-x+3$ ជាបន្ទាត់កាត់តាមចំណុច

| | | |
|---|---|---|
| $x$ | $0$ | $3$ |
| $y$ | $3$ | $0$ |

គេបានមាឌសូលីតបរិវត្តបានពីរង្វិលជុំវិញអ័ក្សអាប់ស៊ីសនៃផ្ទៃដែលខណ្ឌដោយក្រាបតាងអនុគមន៍ $f(x)=x^2+1$ និង $g(x)=-x+3$ ត្រូវនឹង $0\le x\le 1$

កំណត់ដោយ $V=\pi\int_a^b\left[f(x)\right]^2dx-\pi\int_a^b\left[g(x)\right]^2dx$

$$=\pi\int_{-2}^{1}(-x+3)^2dx-\pi\int_{-2}^{1}\left(x^2+1\right)^2dx$$

តាម ម៉ាស៊ីនគិតលេខ $fx$ 991 ES




ចូលការគណនាទូទៅ MODE 1

កំណត់ចេញលទ្ធផលជារ៉ាដ្យង់ SHIFT MODE 4

បញ្ចូលទិន្នន័យ SHIFT x10ˣ ∫ ( − ALPHA ) + 3 ) x² ▶ − 2 ▶ 1 ▶ − SHIFT x10ˣ ∫ ( ALPHA )

បន្ត x² + 1 ) x² ▶ − 2 ▶ 1 = $\frac{117\pi}{5}$

គេបាន $V=\frac{117\pi}{5}$ ឯកតាមាឌ

## ប្រតិបត្តិ

ក . គណនាមាឌសូលីតបរិវត្តបានពីរង្វិលជុំវិញអ័ក្សអាប់ស៊ីសនៃផ្ទៃដែលខណ្ឌដោយក្រាបតាងអនុគមន៍ $f(x)=4-x^2$ និង $g(x)=2-x$ ត្រូវនឹង $-1\le x\le 2$ ។

ខ . $(C)$ ជាក្រាបតាង $f(x)=e^x$ និង $(l)$ ជាបន្ទាត់ប៉ះនឹង $(C)$ ត្រង់ចំណុច $(1\,,e)$ ។

១ . រកសមីការបន្ទាត់ប៉ះ $(l)$ ។

២ .គណនាមាឌសូលីតបរិវត្តបានពីរង្វិលជុំវិញអ័ក្សអាប់ស៊ីសនៃផ្ទៃដែលខណ្ឌដោយក្រាប $(C)$ និង $(l)$ ត្រូវនឹង $0\le x\le 1$ ។

**លំហាត់គំរូទី ៥** : គណនាមាឌសូលីតបរិវត្តបានពីរង្វិលជុំវិញអ័ក្សអាប់ស៊ីសនៃផ្ទៃតាងអនុគមន៍ $y=\sqrt{3-x}$ និង $g(x)=-x+3$ ត្រូវនឹង $0\le y\le\sqrt{3}$ ។




## ចម្លើយ

គេមាន $y=\sqrt{3-x}$

$y^2=3-x$

$x=y^2-3$

នោះមាឌដែលត្រូវរកគឺ

$$V=\pi\int_0^{\sqrt{3}}\left(3-y^2\right)^2 dy$$




តាម ម៉ាស៊ីនគិតលេខ $fx$ 991 ES សន្មត $y$ ជា $x$

ចូលការគណនាទូទៅ [MODE] [1]

កំណត់ចេញលទ្ធផលជារ៉ាដ្យង់ [SHIFT] [MODE] [4]

បញ្ចូលទិន្នន័យ [SHIFT] [×10ˣ] [∫□] [(] [3] [−] [ALPHA] [)] [x²] [)] [x²]

បន្ត [▶] [0] [▶] [√□] [3] [=] $\dfrac{24\pi\sqrt{3}}{5}=26.1187$

គេបាន $V=\dfrac{24\pi\sqrt{3}}{5}=26.1187$ ឯកតាមាឌ

**លំហាត់គំរូទី ៦** : គណនាតម្លៃមធ្យមនៃអនុគមន៍ $y=\sqrt{x}$ នៅលើចន្លោះ $[0\,,4]$ ។

## ចម្លើយ

តម្លៃមធ្យមនៃអនុគមន៍ $y=\sqrt{x}$ នៅលើចន្លោះ $[0\,,4]$ កំណត់ដោយ :

$$y_{av}=\frac{1}{b-a}\int_a^b f(x)\,dx$$

$$=\frac{1}{4-0}\int_0^4\sqrt{x}dx$$




តាម ម៉ាស៊ីនគិតលេខ $fx$ 991 ES

ចូលការគណនាទូទៅ [MODE] [1]

បញ្ចូលទិន្នន័យ [□/□] [1] [▶] [4] [−] [0] [▶] [∫□] [√□] [ALPHA] [)]

បន្ត [▶] [▶] [0] [▶] [4] [=] $\dfrac{4}{3}=1.3333$

គេបាន $y_{av}=\dfrac{4}{3}=1.3333$

**លំហាត់គំរូទី ៧** : គណនាតម្លៃមធ្យមនៃអនុគមន៍ $y=\sin x$ នៅលើចន្លោះ $\left[0\,,\dfrac{\pi}{2}\right]$ ។

## ចម្លើយ

តម្លៃមធ្យមនៃអនុគមន៍ $y=\sin x$ នៅលើចន្លោះ $\left[0\,,\dfrac{\pi}{2}\right]$ កំណត់ដោយ

$$y_{av}=\frac{1}{b-a}\int_a^b f(x)\,dx$$

$$=\frac{1}{\frac{\pi}{2}-0}\int_0^{\frac{\pi}{2}}\sin x dx$$

តាម ម៉ាស៊ីនគិតលេខ $fx$ 991 ES

ចូលការគណនាទូទៅ [MODE] [1]

កំណត់ចេញលទ្ធផលជារ៉ាដ្យង់ [SHIFT] [MODE] [4]

បញ្ចូលទិន្នន័យ [▭/▭] [1] [▶] [▭/▭] [SHIFT] [x10^x] [▶] [2] [▶] [−] [0] [▶]

បន្ត [∫▭] [sin] [ALPHA] [)] [)] [▶] [0] [▶] [▭/▭] [SHIFT] [x10^x] [▶] [2] [=] $\frac{2}{\pi}=0.6366$

គេបាន $y_{av}=\frac{2}{\pi}=0.6366$

## ប្រតិបត្តិ

ក . គណនាតម្លៃមធ្យមនៃអនុគមន៍ $y=\frac{1}{x\sqrt{1-\ln^2 x}}$ នៅលើចន្លោះ $\left[1\,,\sqrt{e}\right]$ ។

ខ . គណនាតម្លៃមធ្យមនៃអនុគមន៍ $y=\sqrt{2x+1}$ នៅលើចន្លោះ $[4\,,12]$ ។

**លំហាត់គំរូទី ៨** : គណនាប្រវែងធ្នូនៃក្រាបតាងអនុគមន៍ $y=f(x)=\frac{4\sqrt{2}}{3}x^{\frac{3}{2}}-1$ ដែលនៅចន្លោះបន្ទាត់ឈរ $x=0$ និង $x=1$ ។

**ចម្លើយ**




គេមាន $y=f(x)=\frac{4\sqrt{2}}{3}x^{\frac{3}{2}}-1$

$$y'=\frac{4\sqrt{2}}{3}\times\frac{3}{2}x^{\frac{3}{2}-1}$$

$$=2\sqrt{2}x^{\frac{1}{2}}$$

$$1+(y')^2=1+\left(2\sqrt{2}x^{\frac{1}{2}}\right)^2$$

$$=1+8x$$




ប្រវែងធ្នូនៃក្រាបតាងអនុគមន៍ $y=f(x)=\frac{4\sqrt{2}}{3}x^{\frac{3}{2}}-1$

ដែលនៅចន្លោះបន្ទាត់ឈរ $x=0$ និង $x=1$ កំណត់ដោយ :

$$L=\int_a^b\sqrt{1+(y')^2}\,dx$$

$$=\int_0^1\sqrt{1+8x}\,dx$$

តាម ម៉ាស៊ីនគិតលេខ $fx$ 991 ES

ចូលការគណនាទូទៅ [MODE] [1]

កំណត់ចេញលទ្ធផលជារ៉ាដ្យង់ [SHIFT] [MODE] [4]

បញ្ចូលទិន្នន័យ [∫▭] [√▭] [1] [+] [8] [ALPHA] [)]

បន្ត [▶] [▶] [0] [▶] [1] [=] $\frac{13}{6}=2.1666$

គេបាន $L=\frac{13}{6}=2.1666$

**ប្រតិបត្តិ :** គណនាប្រវែងធ្នូនៃក្រាបតាងអនុគមន៍ $y=f(x)=\frac{1}{3}(x^2+2)^{\frac{3}{2}}$ ដែលនៅចន្លោះបន្ទាត់ឈរ $x=0$ និង $x=3$ ។

## លំហាត់

១. គណនាមាឌនៃសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអ័ក្ស $x'ox$ នៃផ្ទៃក្រឡាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $y=2x+1$ អ័ក្ស $x'ox$ បន្ទាត់ឈរ $x=1$ និង $x=3$ ។

២. គណនាមាឌនៃសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអ័ក្ស $x'ox$ នៃផ្ទៃក្រឡាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $y=x^2+1$ អ័ក្ស $x'ox$ បន្ទាត់ឈរ $x=0$ និង $x=3$ ។

៣. គណនាមាឌនៃសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអ័ក្ស $x'ox$ នៃផ្ទៃក្រឡាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $y=\sqrt{x}-3$ អ័ក្ស $x'ox$ បន្ទាត់ឈរ $x=4$ និង $x=9$ ។

៤. គណនាមាឌនៃសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអ័ក្ស $x'ox$ នៃផ្ទៃក្រឡាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $f(x)=x^2$ និង $g(x)=4x-x^2$ ។

៥. គណនាមាឌនៃសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអ័ក្ស $x'ox$ នៃផ្ទៃក្រឡាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $f(x)=x^2-2x+3$ និង $g(x)=9-x$ ។

៦. គេលក់បោះដុំស្ករសូកូឡាបានទទួលវិក័យប័ត្រទូទាត់ ចំនួន 1200 រៀងរាល់ថ្ងៃ ។ ស្ករសូកូឡាត្រូវបានលក់បន្តឱ្យអ្នកលក់រាយដោយអត្រាថេរ និង $x$ ជាថ្ងៃបន្ទាប់ពីវិក័យប័ត្រមកដល់ ហើយបញ្ជីទូទាត់កំណត់ដោយ $I(x)=1200-40x$ ។

ក . គណនាមធ្យមប្រចាំថ្ងៃនៃការទូទាត់ ។

ខ . គណនាមធ្យមប្រចាំថ្ងៃនៃថ្លៃលក់ស្ករសូកូឡាបើស្ករសូកូឡាមួយគ្រាប់ថ្លៃ 300 រៀល ។

៧ . ក. គណនាប្រវែងធ្នូនៃក្រាបតាងអនុគមន៍ $y=\frac{x^3}{3}+\frac{1}{4x}$ ពី $x=1$ ទៅ $x=3$ ។

ខ. ឧបមាថា $f(x)=\frac{e^x+e^{-x}}{2}$ ។ បន្ទាត់ជួបអ័ក្សអរដោនេត្រង់ចំណុច $B$ ហើយប៉ះនឹងក្រាបតាង $f$ ត្រង់ចំណុច $A(a\,;\,f(a))$ ដែល $a>0$ ។ ប្រៀបធៀបប្រវែងនៃអង្កត់ $AB$ និង ប្រវែងធ្នូនៃក្រាបតាង $f$ ដែលនៅចន្លោះបន្ទាត់ឈរ $x=0$ និង $x=a$ ។

៨. គណនាអាំងតេក្រាលខាងក្រោម :

ក . $\int_{-2}^{2}(4-x^2)(2+x)^n\,dx$ ខ . $\int_6^8\frac{x}{x^2-6x+8}dx$ គ . $\int_0^1\frac{x^2}{x^2-x-2}dx$

ឃ . $\int_1^3\frac{x-1}{\sqrt{x}}dx$ ង . $\int_0^1\frac{x}{1+3x^2}dx$ ច . $\int_0^{\frac{\pi}{2}}\frac{\sin 2x}{3+\cos^2 x}dx$

៩. គណនាមាឌនៃសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអ័ក្ស $x'ox$ នៃផ្ទៃក្រឡាដែលខណ្ឌដោយក្រាបតាងអនុគមន៍ $f(x)=x+6$ និង $g(x)=x^2$ លើចន្លោះ $x\in[-2;3]$ ។

១០. គណនា

ក . $\int_0^{\frac{\pi}{2}} x^2\cos^2 x dx$ ខ . $\int_1^e \frac{\sin(\pi\ln x)}{x}dx$ គ . $\int_0^{\sqrt{\ln 6}} \frac{x}{e^{-x^2}+e^{x^2}+2}dx$

ឃ . $\int_0^1\left(4-x^2-\sqrt{1-x^2}\right)dx$ ង . $\int_0^1 \frac{dx}{\sqrt{4-x^2}}$ ច . $\int_0^1 \frac{2x}{x^2-x+1}dx$

១១. គណនាមាឌនៃសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអ័ក្ស $x'ox$ នៃផ្ទៃក្រឡាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $y=\sqrt{3-x}$ និងអ័ក្ស $x'ox$ , $(-1\le x\le 2)$ ។

១២. គណនាមាឌនៃសូលីតបរិវត្តកំណត់បានពីរង្វិលចំនួន $360^\circ$ ជុំវិញអ័ក្ស $x'ox$ នៃផ្ទៃក្រឡាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $y=1-x^2$ និងអ័ក្ស $x'ox$ , $x\in[-1;\,1]$ ។

១៣. គណនាមាឌនៃសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអ័ក្ស $x'ox$ នៃផ្ទៃក្រឡាដែលខណ្ឌដោយក្រាបតាងអនុគមន៍ $f(x)=2x^2$ និង $g(x)=4x-x^2$ ។

១៤. គណនាមាឌនៃសូលីតបរិវត្តកំណត់បានពីរង្វិលចំនួន $180^\circ$ ជុំវិញអ័ក្ស $x'ox$ នៃផ្ទៃក្រឡាដែល ខណ្ឌដោយក្រាបតាងអនុគមន៍ $f(x)=8-x^2$ និង $g(x)=x^2$ ។

១៥. គណនាផ្ទៃក្រឡាដែលខណ្ឌដោយក្រាបតាងអនុគមន៍ $y=\sin\frac{\pi}{2}x$ និង $y=x^4$ ។

១៦. គណនាផ្ទៃក្រឡាដែលខណ្ឌដោយក្រាបតាងអនុគមន៍ $y=\sin^3 x$ និង $y=\cos^3 x$ នៅចន្លោះ $x=\frac{\pi}{4}$ និង $x=\frac{5\pi}{4}$ ។

១៧. គណនាផ្ទៃក្រឡាដែលខណ្ឌដោយក្រាបតាងអនុគមន៍ $y=\sin x$ , $0\le x\le\pi$ និង $y=\sin 3x$ , $0\le x\le\pi$ ។

# ជំពូក ៤ សមីការឌីផេរ៉ង់ស្យែល

## មេរៀនទី ១ សមីការឌីផេរ៉ង់ស្យែលលំដាប់ទី ១

### មេរៀនសង្ខេប

សមីការឌីផេរ៉ង់ស្យែលលំដាប់ទី 1 មានរាងទូទៅ:

1. $\frac{dy}{dx}=f(x)$ មានចម្លើយទូទៅ $y=\int f(x)dx+c$

2. $g(y)\frac{dy}{dx}=f(x)$ មានចម្លើយទូទៅ $G(y)=F(x)+c$ ដែល $G(y)=\int g(y)dy$

3. $y'+ay=0$ ឬ $\frac{dy}{dx}+ay=0$ មានចម្លើយទូទៅ $y=Ae^{-ax}$ ($A$ ជាចំនួនថេរ)

4. $y'+ay=p(x),\quad p(x)\neq 0$ មានចម្លើយទូទៅ $y=y_e$ ដែល $y_p$ ជាចម្លើយ នៃសមីការ $y'+ay=0$ និង $y_p$ ជាចម្លើយពិសេសមួយនៃសមីការ $y'+ay=p(x)$

លំហាត់គំរូទី ១ : ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $y'=\dfrac{2x}{x^2+1}$

ចម្លើយ

គេមាន $y'=\dfrac{2x}{x^2+1}$ នាំឱ្យ $\dfrac{dy}{dx}=\dfrac{2x}{x^2+1}$

$$dy=\frac{2x}{x^2+1}dx$$

$$\int dy=\int\frac{2x}{x^2+1}dx$$

$$y=\int\frac{d\left(x^2+1\right)}{x^2+1}$$

$$y=\ln\left(x^2+1\right)+c$$

ដូចនេះ $y=\ln\left(x^2+1\right)+c$ ជាចម្លើយទូទៅនៃសមីការ ដែល $c$ ជាចំនួនថេរណាមួយ ។

ប្រតិបត្តិ : ដោះស្រាយសមីការឌីផេរ៉ង់ស្យែល :

ក . $y'=6x^2+4x+5$ ខ . $y'=xe^{x^2}$

**លំហាត់គំរូទី ២** : រកអនុគមន៍ចម្លើយមួយនៃសមីការឌីផេរ៉ង់ស្យែល $x\dfrac{dy}{dx}-y=2x^2y$ ដែលខ្សែកោងកាត់តាមចំណុច $(x=1\,,\,y=e)$

**ចម្លើយ**

គេមាន $x\dfrac{dy}{dx}-y=2x^2y$ នាំឱ្យ $\dfrac{dy}{y}=\dfrac{\left(2x^2+1\right)dx}{x}$

$$\int\frac{dy}{y}=\int\left(2x+\frac{1}{x}\right)dx$$

$$\ln|y|=x^2+\ln|x|+c$$

ខ្សែកោងចម្លើយកាត់តាមចំណុច $(x=1\,,\,y=e)$

គេបាន $\ln(e)=1+\ln(1)+c$

$$1=1+0+c\Rightarrow C=0$$

ដូចនេះ ចម្លើយមួយនៃសមីការឌីផេរ៉ង់ស្យែល គឺ $\ln|y|=x^2+\ln|x|$

**លំហាត់គំរូទី ៣** : រកចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែល $y'+y=0$ ។ រកចម្លើយពិសេសនៃសមីការនេះតាមលក្ខខណ្ឌ $y(0)=-1\,,\,y(0)=1\,,\,y(1)=1$

**ចម្លើយ**

រកចម្លើយទូទៅ

គេមាន $y'+y=0$

$$y'=-y$$

$$\frac{dy}{y}=-dx$$

$$\int \frac{dy}{y} = -\int dx$$
$$\ln|y| = -x + c$$
$$|y| = e^{(-x+c)}$$
$$y = \pm e^{c} e^{-x}$$

ដូចនេះ $y = Ae^{-x}$ , $A = \pm e^{c}$ ដែល $A$ ជាចំនួនថេរណាមួយ ។

រកចម្លើយពិសេស

+ តាមលក្ខខណ្ឌ $y(0) = -1$ គេបាន $-1 = Ae^{0} \Rightarrow A = -1$

ដូចនេះ $y = -e^{-x}$ ជាចម្លើយពិសេស

+ តាមលក្ខខណ្ឌ $y(0) = 1$ គេបាន $1 = Ae^{0} \Rightarrow A = 1$

ដូចនេះ $y = e^{-x}$ ជាចម្លើយពិសេស

+ តាមលក្ខខណ្ឌ $y(1) = 1$ គេបាន $1 = Ae^{-1} \Rightarrow A = e$

ដូចនេះ $y = e^{-x+1}$ ជាចម្លើយពិសេស

**ប្រតិបត្តិ :** ១ . ដោះស្រាយសមីការ $-y' + 2y = 0$ តាមលក្ខខណ្ឌ $y(3) = -2$

២ . រកអនុគមន៍ចម្លើយនៃសមីការ $3y' + 6y = 0$ ដែលខ្សែកោងតាងអនុគមន៍ចម្លើយកាត់តាមចំណុច $(-4\,,\,2)$ ។

**លំហាត់គំរូទី ៤** : ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $y' - 2y = 8x^2 - 8x \qquad (E)$

## ចម្លើយ

+ ដោះស្រាយសមីការ $y' - 2y = 0$

$$\frac{dy}{dx} = 2y \quad \Rightarrow \frac{dy}{y} = 2dx$$
$$\ln|y| = 2x + c$$
$$y_c = Ae^{2x} \quad , \; A = \pm e^{c}$$




+ ចម្លើយពិសេសនៃ$(E)$ $y_p = ax^2 + bx + c \Rightarrow y_p' = 2ax + b$

នោះ $(E)$ $\quad 2ax + b - 2ax^2 - 2bx - 2c = 8x^2 - 8x$

$$-2ax^2 + (2a - 2b)x + b - 2c = 8x^2 - 8x$$

$$\Rightarrow \begin{cases} -2a = 8 \\ 2a - 2b = -8 \\ b - 2c = 0 \end{cases}$$

យើងប្រើម៉ាស៊ីនគិតលេខ *fx*- 991 ES ដើម្បីដោះស្រាយ

ចូលការដោះស្រាយប្រព័ន្ធសមីការដឺក្រេទី ១មាន ៣អញ្ញាត [MODE] [5] [2]

បញ្ចូលតម្លៃមេគុណ [−] [2] [=] [0] [=] [0] [=] [8] [=]

[2] [=] [−] [2] [=] [0] [=] [−] [8] [=]

បន្ត [0] [=] [1] [=] [−] [2] [=] [0] [=] [=]

គេបាន $a = -4$ [▼] $b = 0$ [▼] $c = 0$

គេបាន $y_p = -4x^2$

ចម្លើយទូទៅនៃសមីការ គឺ $y = y_c + y_p = Ae^{2x} - 4x^2$

## ប្រតិបត្តិ : ដោះស្រាយសមីការ

ក . $y' + y = 2e^x$  ខ . $y' + 2y = x^2$ , $y(0) = 2$  គ . $y' + y = \cos x + \sin x$

## ចម្លើយ

ក . $y' + y = 2e^x \quad (1)$

+ ដោះស្រាយសមីការ $y' + y = 0$

$$\frac{dy}{dx} = -y \quad \Rightarrow \frac{dy}{y} = -dx$$

$$\ln|y| = -x + c$$

$$y_c = Ae^{-x} \quad , \ A = \pm e^c$$

+ ចម្លើយពិសេសនៃ $(1)$ $y_p = ae^x \Rightarrow y'_p = ae^x$

នោះ $(E)$ $\quad ae^x + ae^x = 2e^x$

$$2a = 2 \quad , \quad e^x > 0 \ , \ \forall x$$

$$a = 1$$

គេបាន $y_p = e^x$

ចម្លើយទូទៅនៃសមីការ គឺ $y = y_c + y_p = Ae^{-x} + e^x$

ខ . $y' + 2y = x^2$ , $y(0) = 2 \quad (2)$

+ ដោះស្រាយសមីការ $y' + 2y = 0$

$$\frac{dy}{dx} = -2y \ \Rightarrow \frac{dy}{y} = -2dx$$

$$\ln|y| = -2x + c$$

$$y_c = Ae^{-2x} \quad , \ A = \pm e^c$$




+ ចម្លើយពិសេសនៃ $(2)$ $y_p = ax^2 + bx + c \Rightarrow y'_p = 2ax + b$

នោះ $(2)$ $\quad 2ax + b + 2ax^2 + 2bx + 2c = x^2$

$$2ax^2 + (2a + 2b)x + b + 2c = x^2$$

$$\begin{cases} 2a = 1 \\ 2a + 2b = 0 \\ b + 2c = 0 \end{cases}$$

យើងប្រើម៉ាស៊ីនគិតលេខ $fx$ 991 ES ដើម្បីដោះស្រាយ

ចូលការដោះស្រាយប្រព័ន្ធសមីការដឺក្រេទី ១មាន ៣អញ្ញាត [MODE] [5] [2]

បញ្ចូលតម្លៃមេគុណ [2] [=] [0] [=] [0] [=] [1] [=]

[2] [=] [2] [=] [0] [=] [0] [=]

បន្ត [0] [=] [1] [=] [2] [=] [0] [=] [=]

គេបាន $a=\frac{1}{2}$ ⊙ $b=-\frac{1}{2}$ ⊙ $c=\frac{1}{4}$

គេបាន $y_p=\frac{1}{2}x^2-\frac{1}{2}x+\frac{1}{4}$

ចម្លើយទូទៅនៃសមីការ គឺ $y=y_c+y_p=Ae^{-2x}+\frac{1}{2}x^2-\frac{1}{2}x+\frac{1}{4}$

តាមលក្ខខណ្ឌ $y(0)=2$ គេបាន $A+\frac{1}{4}=2\Rightarrow A=2-\frac{1}{4}=\frac{7}{4}$

ចម្លើយដោយឡែកនៃសមីការ គឺ $y=\frac{7}{4}e^{-2x}+\frac{1}{2}x^2-\frac{1}{2}x+\frac{1}{4}$

គ . $y'+y=\cos x+\sin x$

+ ដោះស្រាយសមីការ $y'+y=0$

$$\frac{dy}{dx}=-y \quad \Rightarrow \frac{dy}{y}=-dx$$

$$\ln|y|=-x+c$$

$$y_c=Ae^{-x} \quad , \ A=\pm e^c$$

+ ចម្លើយពិសេសនៃ$(3)$ $y=a\cos x+b\sin x\Rightarrow y'=-a\sin x+b\cos x$

នោះ$(3)$ $-a\sin x+b\cos x+a\cos x+b\sin x=\cos x+\sin x$

$$(a+b)\cos x+(-a+b)\sin x=\cos x+\sin x$$

$$\Rightarrow\begin{cases} a+b=1 \\ -a+b=1\end{cases}$$




យើងប្រើម៉ាស៊ីនគិតលេខ $fx$ 991 ES ដើម្បីដោះស្រាយ

ចូលការដោះស្រាយប្រព័ន្ធសមីការដឺក្រេទី ១មាន ២អញ្ញាត MODE 5 1

បញ្ចូលតម្លៃមេគុណ 1 = 1 = 1 =

− 1 = 1 = 1 = =

គេបាន $a=0$ ⊙ $b=1$

ដូចនេះចម្លើយទូទៅនៃសមីការ គឺ $y=y_c+y_p=Ae^{-x}+\sin x$

**លំហាត់គំរូទី ៥** : នំដុតដែលគេទើបលើកចេញពីចង្ក្រានមានសីតុណ្ហភាព $120^\circ C$ ។ គេយកនំនេះមកដាក់ក្នុងបន្ទប់មួយមានសីតុណ្ហភាព $28^\circ C$ ។ គេឃើញថា 3 នាទីក្រោយមកសីតុណ្ហភាពរបស់នំធ្លាក់ចុះនៅ $80^\circ C$ ។

ក . សរសេរសមីការឌីផេរ៉ង់ស្យែលដែលទាក់ទង់នឹងសីតុណ្ហភាព$T$ របស់នំក្នុងខណៈពេល $t$ និងលក្ខខណ្ឌចំណោទដើម ។

ខ . គណនា សីតុណ្ហភាពរបស់នំក្នុងខណៈពេល $t$ ។

គ . គណនារយៈពេលដែលសីតុណ្ហភាពរបស់នំថយចុះដល់ $30^\circ C$ ។

## ចម្លើយ

ក . អត្រាថយចុះនៃសីតុណ្ហភាពគឺ $-\frac{dT}{dt}$ ដោយអត្រាថយចុះនេះសមាមាត្រនឹងផលដក

រវាងសីតុណ្ហភាពនំនិងសីតុណ្ហភាពបរិយាកាសជុំវិញ នោះគេបានសមីការ
ឌីផេរ៉ង់ស្យែល

$-\frac{dT}{dt}=k(T-M)$ តាមលក្ខខណ្ឌដើម $T(0)=T_0=120^\circ C$

ដោយសីតុណ្ហភាព $M=28^\circ C$ នោះគេបាន $\frac{dT}{dt}=-k(T-28)$ , $T(0)=120$

ខ . គណនា សីតុណ្ហភាពរបស់នំក្នុងខណៈពេល $t$

គេមាន $\frac{dT}{dt}=-k(T-28)\Rightarrow\frac{dT}{T-28}=-kdt$

$$\ln|T-28|=-kt+c$$

$$T-28=e^{-kt+c}$$

$$T(t)=Ae^{-kt}+28$$

ដោយ $T(0)=T_0=120^\circ C$ នោះ $120=Ae^{-k(0)}+28$

$$A=92$$

$$T(t)=92e^{-kt}+28$$

ដោយ 3 នាទីក្រោយ មកសីតុណ្ហភាពរបស់នំធ្លាក់ចុះពី$120^\circ C$ ទៅ $80^\circ C$ នោះគេបាន

$$80=92e^{-k(3)}+28$$

$$92e^{-k(3)}=52$$

$$e^{-k(3)}=\frac{52}{92}$$

$$-3k=\ln\left(\frac{52}{92}\right)$$

$$k=-\frac{1}{3}\ln\left(\frac{52}{92}\right)$$




យើងប្រើ ម៉ាស៊ីនគិតលេខ $fx$ 350 ES ដោយកំណត់ $t=x$

ចូលការគណនាទូទៅ [MODE] [1]

[(−)] [▭/▭] [1] [▶] [3] [▶] [ln] [▭/▭] [5] [2] [▶] [9] [2] [▶] [)] [=] $k=0.19$

ដូចនេះ $T(t)=92e^{-0.19t}+28$

គ . គណនារយៈពេលដែលសីតុណ្ហភាពរបស់នំថយចុះដល់ $30^\circ C$

គេបាន $30=92e^{-0.19t}+28$

$$30=92e^{-0.19t}+28$$

$$92e^{-0.19t}=2$$

$$e^{-0.19t}=\frac{2}{92}$$

$$-0.19t=\ln\left(\frac{2}{92}\right)$$

$$t=\frac{-1}{0.19}\ln\left(\frac{2}{92}\right)$$



យើងប្រើ ម៉ាស៊ីនគិតលេខ $fx$ 350 ES

ចូលការគណនាទូទៅ [MODE] [1]

[−] [▭] [1] [▶] [0] [·] [1] [9] [▶] [ln] [▭] [2] [▶] [9] [2] [▶] [)]

[=] [S⇔D] $t = 20.15263158$ [°'''] 20 នាទី 9 វិនាទី

ដូចនេះ $t = 20$ នាទី 9 វិនាទី

**ប្រតិបត្តិ** : មុនពេលចេញទៅធ្វើការ លោកគ្រូសាលីត្រូវពិសាកាហ្វេមួយកែវនៅក្នុងបន្ទប់ ដែលមានសីតុណ្ហភាព $28^{\circ}C$ ។កាហ្វេដែលទើបចាក់ដាក់កែវមានសីតុណ្ហភាព $80^{\circ}C$ ។ 15 នាទីក្រោយមក សីតុណ្ហភាពថយចុះនៅ $48^{\circ}C$ ។កាហ្វេដែលលោកគ្រូអាចហូប បានមិនធ្វើឱ្យរលាកមាត់គាត់គឺនៅ សីតុណ្ហភាព $40^{\circ}C$ ។

តើគាត់ត្រូវរង់ចាំប៉ុន្មាននាទីទៀតទើបគាត់អាចហូបកាហ្វេបាន ?

**លំហាត់គំរូទី ៦** :គេសិក្សាអំពីកំណើននៃការបណ្ដុះបាក់តេរីក្នុងមជ្ឈដ្ឋានមួយ ។ តាង $N(t)$ ជាអនុគមន៍នៃ $t$ ជាចំនួនបាក់តេរីដែលមាននៅខណៈពេល $t$ ($t$ គិតជាម៉ោង) ។ គេដឹងថាចំនួនបាក់តេរីកើនឡើង 10% ក្នុង 1 ម៉ោង ។

ក . បង្ហាញថាចំពោះគ្រប់ $t$ ជាចំនួនពិតវិជ្ជមាន $N(t)$ ផ្ទៀងផ្ទាត់ :

$$N(t+1)-N(t)=0.1N(t)$$

ខ . គេចាត់ទុកថា $N(t+1)-N(t)$ ខិតទៅរក $N'(t)$ ដែលជាដេរីវេនៃ $N$ ។ គណនាចំនួនបាក់តេរីនៅខណៈពេល $t=3h$ បើគេដឹងថាចំនួនបាក់តេរីនៅពេលចាប់ផ្ដើមបណ្ដុះមាន $N_0=10^4$ ។

**ចម្លើយ**

ក . ដោយចំនួនបាក់តេរីមាន $N(t)$ នៅម៉ោង $t$ ហើយកើនបាន10% ក្នុង 1 ម៉ោង

នោះមួយម៉ោងក្រោយមកចំនួនបាក់តេរីមាន $N(t+1)=N(t)+\frac{10}{100}N(t)$

ដូចនេះ $N(t+1)-N(t)=0.1N(t)$

ខ . គណនាចំនួនបាក់តេរីនៅខណៈពេល $t=3h$

ដោយ $N'(t)=\lim_{t\to 0}\frac{N(t+1)-N(t)}{t+1-t}$

$N'(t)=0.1N(t)$ ជាសមីការឌីផេរ៉ង់ស្យែល

$$\frac{dN}{dt}=0.1N \Rightarrow \frac{dN}{N}=0.1dt$$

$$\ln|N|=0.1t+c$$

$$N=Ae^{0.1t}$$

ដោយ $N(0)=N_0=10^4$

នោះ $10^4=Ae^{0.1(0)} \Rightarrow A=10^4$

$$\Rightarrow N(t)=10^4e^{0.1t}$$



$t=3 \quad : \quad N(3)=10^4 e^{0.3}$

យើងប្រើ ម៉ាស៊ីនគិតលេខ $fx$ 350 ES

ចូលការគណនាទូទៅ MODE 1

1 0 $x^{\blacksquare}$ 4 ▶ SHIFT ln 0 • 3 ▶ = $N(3)=13498$ បាក់តេរី ។

**ប្រតិបត្តិ** :គេដឹងថាកំណើននៃចំនួនបាក់តេរីសមាមាត្រនឹងចំនួនបាក់តេរីដែលកំពុងមាន។ ឧបមាថា ចំនួនបាក់តេរីកើនឡើងទ្វេដងរាល់12 ម៉ោង ។ គណនារយៈពេលដែលចំនួនបាក់តេរីកើនឡើង 5 ដង ពីចំនួនដែលមានពីដំបូង ។

# លំហាត់

១ . ដោះស្រាយសមីការឌីផេរ៉ង់ស្យែល :

ក . $y' = 2x^2 - x + 1$ ខ . $y' = e^{-2x}$ គ . $y' = \dfrac{2x}{x^2+1}$

ឃ. $y' = \dfrac{2x}{x^2+1}$ កំណត់លើ $]-1\,;1[$ ង. $xy' = 1$ កំណត់លើ $]0\,;+\infty[$

២ . ដោះស្រាយសមីការឌីផេរ៉ង់ស្យែលតាមលក្ខខណ្ឌដែលឱ្យ :

ក . $\dfrac{y'}{y} = \cos x$ ; $y\left(\dfrac{\pi}{2}\right) = 0$ ខ . $y' = e^{2x}$ ; $y(0) = 5$

គ . $(3x^2 - 2)y' = 6x$ ; $y(1) = 4$ ឃ . $\dfrac{y'}{\tan x} = 1$; $y(0) = 0$

៣ . ដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី ១ :

ក . $\dfrac{dy}{dx} + 2y = 0$ ខ . $3\dfrac{dy}{dx} + y = 0$ គ . $2y' - 3y = 0$ ឃ . $y' - y\sqrt{2} = 0$

៤ . ដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី ១ :

ក . $-y' + 2y = 0$ ; $y(3) = -2$ ខ . $2y' + y = 0$ ; $y(\ln 4) = \dfrac{1}{5}$

គ . $7y' + 4y = 0$ ; $y(7) = e^5$ ឃ . $2y' - 5y = 0$; $y(1) = -3$

៥ . ចូរបង្ហាញថាអនុគមន៍នីមួយៗខាងក្រោមជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែលដែលនៅខាងស្តាំវា :

ក . $y = x + e^x$ ; $y' - y = 1 - x$ ខ . $y = e^{3x} - x - 1$ ; $y' - 3y = 3x + 2$

គ . $y = \sin x + \cos x$ ; $y' + y = 2\cos x$ ឃ . $y = x + \ln x$ ; $xy' - y = 1 - \ln x$

៦ . គេឱ្យសមីការឌីផេរ៉ង់ស្យែល: $(E) : y' + 2y = x^2$

ក . កំណត់ពហុធា $g$ មានដឺក្រេទី ២ ដែលជាចម្លើយពិសេសនៃ $(E)$ ។

ខ . តាង $h$ ជាអនុគមន៍ដែល $h(x) = f(x) - g(x)$ ។ បើ $h$ ជាចម្លើយនៃសមីការ $y' + 2y = 0$ នោះបង្ហាញថា $f$ ជាចម្លើយទូទៅនៃ $(E)$ ។

គ . ដោះស្រាយសមីការ $y' + 2y = 0$ រួចទាញរកអនុគមន៍ $f$ ជាចម្លើយទូទៅនៃ $(E)$ ។

៧ . គេឱ្យសមីការឌីផេរ៉ង់ស្យែល: $(E) : y' - 2y = \dfrac{-2}{1+e^{2x}}$

ក . ដោះស្រាយសមីការ $y' + 2y = 0$ ដែលផ្ទៀងផ្ទាត់ $y(0) = 1$ ។

ខ . តាង $f$ ជាអនុគមន៍មានដេរីវេលើ $\mathbb{R}$ ដែល $f(x) = e^{2x}g(x)$ គណនា $f'(x)$ ជាអនុគមន៍នៃ $g(x)$ និង $g'(x)$ ។

គ . បង្ហាញថា $f$ ជាចម្លើយទូទៅនៃ $(E)$ លុះត្រាតែ $g'(x) = \dfrac{-2e^{-2x}}{1+e^{-2x}}$ ។

ឃ . ទាញរកអនុគមន៍ $g(x)$ ជាអនុគមន៍នៃ $f(x)$ ដែល $f$ ជាចម្លើយនៃ $(E)$ ។

៨ . ដោះស្រាយសមីការឌីផេរ៉ង់ស្យែល :

ក . $\frac{dy}{dx}-y=e^{3x}$ ខ . $\frac{dy}{dx}+y=\frac{1}{1+e^{2x}}$ គ . $y'+y=1$ ឃ . $y'+y=\sin x$

៩ . ដោះស្រាយសមីការឌីផេរ៉ង់ស្យែលតាមលក្ខខណ្ឌ :

ក . $y'-y=1$ ; $y(0)=1$ ខ . $y'+2y=1$ ; $y(0)=0$

១០ . ដោះស្រាយសមីការឌីផេរ៉ង់ស្យែល :

ក . $\frac{dy}{dx}=\sin 5x$ ខ . $dy+e^{3x}dx=0$ គ . $e^{x}\frac{dy}{dx}=2x$

ឃ . $(x+1)y'=x+6$ ង . $\frac{dy}{dx}-y^{2}=-9$ ; $y(0)=3$

១១ . គេដាក់ទឹក 100 លីត្រ ក្នុងធុងមួយនិងអំបិល $10kg$ ដែលត្រូវលាយក្នុងធុងនោះ ។ ល្បាយអំបិលគឺ $0.03kg$ នៃអំបិលក្នុងទឹកមួយលីត្រត្រូវបង្ហូរចូលក្នុងធុងមួយទៀតដោយអត្រា $4\ell/\min$ ។ ល្បាយចម្រុះនៅក្នុងធុង ត្រូវបង្ហូរចេញដោយអត្រា $8\ell/min$ ។

ក . រកចំណោទលក្ខខណ្ឌដើមដើម្បីគណនាអំបិល $Q(t)$ នៅក្នុងធុង ។

ខ . គណនាអំបិល $Q(t)$ ក្នុងធុងរហូតធុងដើមបង្ហូរអស់ ។

១២ . បើ $y$ ជាអនុគមន៍តម្លៃទំនិញមួយដែលប្រែប្រួលតាមពេលវេលា ។ $y'$ ជាអត្រាបម្រែបម្រួលនៃអនុគមន៍ $y$ ក្នុងខណៈពេល $t$ ។ គេដឹងថាអនុគមន៍តម្រូវការមុខទំនិញនេះគឺ $D=3000-7y-65y'$ និងអនុគមន៍ផ្គត់ផ្គង់មុខទំនិញនេះគឺ $S=1600+3y+60y'$ ។

ក . គណនា អនុគមន៍តម្លៃទំនិញ កាលណាអនុគមន៍តម្រូវការស្មើនឹងអនុគមន៍ផ្គត់ផ្គង់។

ខ . រកអនុគមន៍តម្លៃទំនិញ បើនៅពេល $t=0$ ទំនិញមានតម្លៃ $y=100$ ។

១៣ .លោកសារីបានសម្រេចចិត្តថានឹងឈប់ជក់បារី ដើម្បីថែរក្សាសុខភាព និងធ្វើការសន្សំប្រាក់ឡើងវិញ ។ គាត់ជក់ក្នុងមួយថ្ងៃ ២ កញ្ចប់ បើគិតជាប្រាក់គាត់ត្រូវចំណាយអស់ ៣ម៉ឺនរៀលក្នុងមួយសប្តាហ៍។ ឧបមាថាគាត់បញ្ចូលប្រាក់នេះជារៀងរាល់សប្តាហ៍ក្នុងគណនីសន្សំនៃធនាគារ នោះគាត់ទទួលបានអត្រាការប្រាក់សមាស 10% ក្នុង ១ ឆ្នាំ ។ តើគាត់ទទួលបានប្រាក់ទាំងអស់ ប៉ុន្មាន បើគាត់ព្យាយាមផ្ទេរប្រាក់នេះចូលធនាគារក្នុងរយៈពេល ៣០ ឆ្នាំ ។

មេរៀនទី

២

# សមីការឌីផេរ៉ង់ស្យែលលំដាប់ទី ២

## មេរៀនសង្ខេប

1. សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី 2 អូម៉ូហ្សែនមានរាងទូទៅ $y''+by'+c=0$ មានសមីការ $\lambda^2+b\lambda+c=0$ ជាសមីការសម្គាល់។
2. សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី 2 មិន អូម៉ូហ្សែនមានរាងទូទៅ $y''+by'+c=p(x)\quad(E)$ ដែល $p(x)\neq 0$ ។ចម្លើយទូទៅនៃសមីការ $(E)$ គឺ $y=y_c+y_p$ ដែល $y_c$ ជាចម្លើយទូទៅនៃសមីការ $y''+by'+c=0$ និង $y_p$ ជាចម្លើយពិសេសនៃ $(E)$ ។

**លំហាត់គំរូទី ១** : ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $y''+2y'-8y=0 \quad (E)$

**ចម្លើយ**




\+ សមីការ $(E)$ មានសមីការសម្គាល់ $\lambda^2+2\lambda-8=0$

យើងប្រើម៉ាស៊ីនគិតលេខ *fx* 991 ES ដើម្បីដោះស្រាយ

ចូលការដោះស្រាយសមីការដឺក្រេទី ២ MODE 5 3

បញ្ចូលតម្លៃមេគុណ 1 = 2 = − 8 = =

គេបាន $\lambda_1=2$ និង ▼ $\lambda_2=-4$

នោះសមីការ $(E)$ អាចសរសេរ $(y'+4y)'-2(y'+4y)=0$

តាង $Z=y'+4y$ គេបាន $Z'-2Z=0$

$$Z'=2Z$$

$$\frac{dZ}{Z}=2dx$$

$$\ln|Z|=2x+c$$

$$Z=c_1e^{2x} \quad ; c_1=\pm e^c$$

ដោយ $Z=y'+4y$ គេបាន $y'+4y=c_1e^{2x}$

\+ ដោះស្រាយសមីការ $y'+4y=c_1e^{2x} \quad (i)$

ដោះស្រាយសមីការ $y'+4y=0$ គេបាន

$$\frac{dy}{dx}=-4y$$

$$\frac{dy}{y}=-4dx$$

$$\ln|y|=-4x+c$$

$$y=c_2e^{-4x} \quad ; c_2=\pm e^c$$

ធ្វើបម្រែបម្រួលចំនួនថេរ $c_2$

មាន $y=c_2(x)e^{-4x}$ នាំឱ្យ $y'=c_2'(x)e^{-4x}-4c_2(x)e^{-4x}$

$$(i) \quad c_2'(x)e^{-4x}-4c_2(x)e^{-4x}+4c_2(x)e^{-4x}=c_1e^{2x}$$

$$c_2'(x)e^{-4x}=c_1e^{2x}$$

$$c_2'(x)=c_1e^{6x}$$

$$c_2(x)=\int c_1e^{6x}dx$$

$$=\frac{c_1e^{6x}}{6}+A$$

$$=Be^{6x}+A \quad ; B=\frac{e^{6x}}{6}$$

ដូចនេះ $y=\left(Be^{6x}+A\right)e^{-4x}=Ae^{-4x}+Be^{2x}$ ជាចម្លើយទូទៅនៃសមីការ $(E)$

**លំហាត់គំរូទី ២** : ក . ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $y''+y'-2y=0 \quad (E)$

ខ . រកចម្លើយពិសេសមួយនៃសមីការ $(E)$ បើខ្សែកោងតាងគន្លងតាងនៃអនុគមន៍ចម្លើយកាត់តាមចំណុច $(x=0, y=1)$ ហើយបន្ទាត់ប៉ះនឹងខ្សែកោងត្រង់ចំណុចនោះមានមេគុណប្រាប់ទិសស្មើនឹង $4$ ។




**ចម្លើយ** អនុគមន៍

ក . សមីការ $(E)$ មានសមីការសម្គាល់ $\lambda^2+\lambda-2=0$

យើងប្រើម៉ាស៊ីនគិតលេខ *fx* 991 ES ដើម្បីដោះស្រាយ

ចូលការដោះស្រាយសមីការដឺក្រេទី ២ [MODE] [5] [3]

បញ្ចូលតម្លៃមេគុណ [1] [=] [1] [=] [(−)] [2] [=] [=]

គេបាន $\lambda_1=1$ និង [▼] $\lambda_2=-2$ ជាចំនួនពិតពីរផ្សេងគ្នា

ដូចនេះ ចម្លើយទូទៅនៃ សមីការ $(E)$ $y=Ae^{-2x}+Be^{x}$

ខ . រកចម្លើយពិសេសមួយនៃសមីការ $(E)$

+ បើ $(C)$ ជាខ្សែកោងគន្លងតាង អនុគមន៍ចម្លើយកាត់តាមចំណុច $(x=0, y=1)$

នោះគេបាន $A+B=1 \quad (1)$

+ មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះនឹង$(C)$ គឺ $y'=-2Ae^{-2x}+Be^{x}$

ដោយ $x=0$ , $y'=4$ គេបាន $-2A+b=4 \quad (2)$

គេបានប្រព័ន្ធសមីការ $\begin{cases} A+B=1 & (1) \\ -2A+B=4 & (2) \end{cases}$

យើងប្រើម៉ាស៊ីនគិតលេខ fx 991 ES ដើម្បីដោះស្រាយ

ចូលការដោះស្រាយសមីការដឺក្រេទី ១មាន ២ អញ្ញាត [MODE] [5] [1]

បញ្ចូលតម្លៃមេគុណ [1] [=] [1] [=] [1] [=] [(−)] [2] [=] [1] [=] [4] [=] [=]

គេបាន $A=-1$ និង [▼] $B=2$

ដូចនេះ $y'=2e^{-2x}+2e^{x}$ ជាចម្លើយពិសេស នៃសមីការ $(E)$ តាមលក្ខខណ្ឌដើម

**ប្រតិបត្តិ :** ១ . ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

ក . $3y''+10y'-3y=0$ ខ . $3y''-2y'=0$

២ . ដោះស្រាយសមីការឌីផេរ៉ង់ស្យែលតាមលក្ខខណ្ឌដើម

$y''-2y'-3y=0$ , $y(0)=-1$ , $y'(1)=\frac{1}{e}$

**លំហាត់គំរូទី ៣** : ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $y''+4y'+4y=0 \quad (E)$

**ចម្លើយ**

+ សមីការ $(E)$ មានសមីការសម្គាល់ $\lambda^2+4\lambda+4=0$

យើងប្រើម៉ាស៊ីនគិតលេខ *fx* 991 ES ដើម្បីដោះស្រាយ

ចូលការដោះស្រាយសមីការដឺក្រេទី ២ [MODE] [5] [3]




បញ្ចូលតម្លៃមេគុណ [1] [=] [4] [=] [4] [=] [=]

គេបាន $\lambda_1 = \lambda_2 = -2$

នោះសមីការ $(E)$ អាចសរសេរ $(y' + 2y)' + 2(y' + 2y) = 0 \quad (i)$

តាង $Z = y' + 2y$ គេបាន $Z' + 2Z = 0$

$$Z' = -2Z$$

$$\frac{dZ}{Z} = -2dx$$

$$\ln|Z| = -2x + c$$

$$Z = Ae^{-2x} \quad ; A = \pm e^{c}$$

គេបាន $y' + 2y = Ae^{-2x} \quad (ii)$

\+ ដោះស្រាយសមីការ $y' + 2y = c_1 e^{-2x} \quad (ii)$

ដោះស្រាយសមីការ $y' + 2y = 0$ គេបាន

$$\frac{dy}{dx} = -2y$$

$$\frac{dy}{y} = -2dx$$

$$\ln|y| = -2x + c$$

$$y = c_1 e^{-2x} \quad ; c_1 = \pm e^{c}$$

ធ្វើបម្រែបម្រួលចំនួនថេរ $c_1$

មាន $y = c_1(x)e^{-2x}$ នាំឱ្យ $y' = c_1'(x)e^{-2x} - 2c_1(x)e^{-2x}$

$$(i) \quad c_1'(x)e^{-2x} - 2c_1(x)e^{-2x} + 2c_1(x)e^{-2x} = Ae^{2x}$$

$$c_1'(x)e^{-2x} = Ae^{2x}$$

$$c_1'(x) = A$$

$$c_1(x) = Ax + B$$

ដែល $B$ ជាចំនួនថេរ

ដូចនេះ $y = (Ax + B)e^{-2x}$ ជាចម្លើយទូទៅនៃសមីការ $(E)$ ដែល $A, B$ ជាចំនួនថេរ

**លំហាត់គំរូទី ៤** : ក . ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y'' + 2y' + y = 0$ តាម លក្ខខណ្ឌដើម $y(\ln 2) = \frac{1}{2}$ និង $y'(\ln 2) = -\frac{1}{2}$

## ចម្លើយ

\+ សមីការ$(E): y'' + 2y' + y = 0$ មានសមីការសម្គាល់ $\lambda^2 + 2\lambda + 1 = 0$

យើងប្រើម៉ាស៊ីនគិតលេខ *fx* 991 ES ដើម្បីដោះស្រាយ

ចូលការដោះស្រាយសមីការដឺក្រេទី ២ [MODE] [5] [3]

បញ្ចូលតម្លៃមេគុណ [1] [=] [2] [=] [1] [=] [=]

គេបាន $\lambda_1 = \lambda_2 = -1$

ដូចនេះ ចម្លើយទូទៅនៃ សមីការ $(E)$ គឺ $y=(Ax+B)e^{-x}$

+ តាមលក្ខខណ្ឌដើម

$y(\ln 2)=\frac{1}{2}$ គេបាន $\frac{1}{2}=A\ln 2e^{-\ln 2}+Be^{-\ln 2}$

$$\frac{1}{2}=\frac{1}{2}A\ln 2+\frac{1}{2}B$$

$$A\ln 2+B=1 \quad (i)$$

ដោយ $y=(Ax+B)e^{-x}$ នាំឱ្យ $y'=Ae^{-x}-Axe^{-x}-Be^{-x}$

គេមាន $y'(\ln 2)=-\frac{1}{2}$ គេបាន $-\frac{1}{2}=Ae^{-\ln 2}-A\ln 2e^{-\ln 2}-Be^{-\ln 2}$

$$-\frac{1}{2}=\frac{1}{2}A-\frac{1}{2}A\ln 2-\frac{1}{2}B$$

$$(1-\ln 2)A-B=-1 \quad (ii)$$




គេបានប្រព័ន្ធសមីការ $\begin{cases} A\ln 2+B=1 & (i) \\ (1-\ln 2)A-B=-1 & (ii) \end{cases}$

យើងប្រើម៉ាស៊ីនគិតលេខ $fx$ 991 ES ដើម្បីដោះស្រាយ

ចូលការដោះស្រាយសមីការដឺក្រេទី ១មាន ២ អញ្ញាត [MODE] [5] [1]

បញ្ចូលតម្លៃមេគុណ [ln] [2] [=] [1] [=] [1] [=] [1] [−] [ln] [2] [=] [−] [1] [=] [−] [1] [=] [=]

គេបាន $A=0$ និង [▼] $B=1$

ដូចនេះ $y'=e^{-x}$ ជាចម្លើយពិសេស នៃសមីការ $(E)$ តាមលក្ខខណ្ឌដើម ។

**ប្រតិបត្តិ :** ដោះស្រាយសមីការឌីផេរ៉ង់ស្យែលតាមលក្ខខណ្ឌដើម

$$4y''-4y'+y=0\ ,\ \ y(0)=-3\ ,\ y'(1)=2$$

**លំហាត់គំរូទី ៥** : ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y''+2y'+2y=0$

**ចម្លើយ**

+ សមីការ$(E): y''+2y'+2y=0$ មានសមីការសម្គាល់ $\lambda^2+2\lambda+2=0$

យើងប្រើម៉ាស៊ីនគិតលេខ $fx$ 991 ES Plus ដើម្បីដោះស្រាយ

ចូលការដោះស្រាយសមីការដឺក្រេទី ២ [MODE] [5] [3]

បញ្ចូលតម្លៃមេគុណ [1] [=] [2] [=] [2] [=] [=]

គេបាន $\lambda_1=-1-i$ និង [▼] $\lambda_2=-1+i$

ដូចនេះ ចម្លើយទូទៅនៃ សមីការ $(E)$ $y=e^{-x}(C\cos x+D\sin x)$

**លំហាត់គំរូទី ៦** : ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y''+4y'+8y=0$

តាមលក្ខខណ្ឌដើម $y(0)=-3\ ,\ y'(0)=2$

**ចម្លើយ**

+ សមីការ$(E): y''+4y'+8y=0$ មានសមីការសម្គាល់ $\lambda^2+4\lambda+8=0$

យើងប្រើម៉ាស៊ីនគិតលេខ $fx$ 991 ES Plus ដើម្បីដោះស្រាយ




ចូលការដោះស្រាយសមីការដឺក្រេទី ២ [MODE] [5] [3]

បញ្ចូលតម្លៃមេគុណ [1] [=] [4] [=] [8] [=] [=]

គេបាន $\lambda_1 = -2-2i$ និង [▼] $\lambda_2 = -2+2i$

នោះចម្លើយទូទៅនៃ សមីការ $(E)$ $y = e^{-2x}\left(C\cos 2x + D\sin 2x\right)$

+ តាមលក្ខខណ្ឌដើម

$y(0)=1$ គេបាន $C=1$

ដោយ $y = e^{-2x}\left(C\cos 2x + D\sin 2x\right)$ នាំឱ្យ

$$y' = -2Ce^{-2x}\cos 2x - 2De^{-2x}\sin 2x - 2Ce^{-2x}\sin 2x + 2De^{-2x}\cos 2x$$

$$= (2D-2C)e^{-2x}\cos 2x - (2D+2C)e^{-2x}\sin 2x$$

គេមាន $y'(0)=2$ គេបាន $2D-2C=2$ , $C=1$

នាំឱ្យ $D=2$

ដូចនេះ $y = e^{-2x}\left(\cos 2x + 2\sin 2x\right)$ ជាចម្លើយពិសេស នៃសមីការ $(E)$ តាមលក្ខខណ្ឌដើម

**លំហាត់គំរូទី ៧** : គេមានសមីការឌីផេរ៉ង់ស្យែល $y'' - 2y' - 3y = 6x^2 - x \quad (E)$

ក . កំណត់ចំនួនពិត $a,b$ និង $c$ ដើម្បីឱ្យអនុគមន៍ $y_p = ax^2 + bx + c$ ជាចម្លើយពិសេសនៃសមីការ$(E)$ ។

ខ . រកចម្លើយទូទៅ $y_c$ នៃសមីការ $y'' - 2y' - 3y = 0$ ។

គ . ផ្ទៀងផ្ទាត់ថា $y = y_p + y_c$ ជាចម្លើយទូទៅនៃសមីការ$(E)$រួចទាញរក ចម្លើយទូទៅនៃសមីការ$(E)$ ។

ចម្លើយ

ក . កំណត់ចំនួនពិត $a,b$ និង $c$

ដោយ $y_p = ax^2 + bx + c$ គេបាន $y'_p = 2ax + b$ , $y''_p = 2a$

នោះ $y'' - 2y' - 3y = 2a - 2(2ax+b) - 3(ax^2 + bx + c)$

គេបាន $2a - 4ax - 2b - 3ax^2 - 3bx - 3c = 6x^2 - x$

$$-3ax^2 - (4a+3b)x + 2a - 2b - 3c = 6x^2 - x$$

នាំឱ្យ $\begin{cases} -3a = 6 \\ 4a + 3b = 1 \\ 2a - 2b - 3c = 0 \end{cases}$

យើងប្រើម៉ាស៊ីនគិតលេខ *fx* 991 ES ដើម្បីដោះស្រាយ

ចូលការដោះស្រាយប្រព័ន្ធសមីការដឺក្រេទី ១មាន ៣អញ្ញាត [MODE] [5] [2]

បញ្ចូលតម្លៃមេគុណ [−] [3] [=] [0] [=] [0] [=] [6] [=]

[4] [=] [3] [=] [0] [=] [1] [=]

បន្ត [2] [=] [−] [2] [=] [−] [3] [=] [0] [=] [=]

គេបាន $a=-2$ [▼] $b=3$ [▼] $c = -\dfrac{10}{3}$

នោះចម្លើយពិសេសនៃ សមីការ $(E)$ គឺ $y_p=-2x^2+3x-\dfrac{10}{3}$

ខ . រកចម្លើយទូទៅ $y_c$ នៃសមីការ $y''-2y'-3y=0$

សមីការ $y''-2y'-3y=0$ មានសមីការសម្គាល់ $\lambda^2-2\lambda-3=0$

យើងប្រើម៉ាស៊ីនគិតលេខ *fx*- 991 ES Plus ដើម្បីដោះស្រាយ

ចូលការដោះស្រាយសមីការដឺក្រេទី ២ MODE 5 3

បញ្ចូលតម្លៃមេគុណ 1 = − 2 = − 3 = =

គេបាន $\lambda_1=-1$ និង ▼ $\lambda_2=-3$

នោះចម្លើយទូទៅនៃ សមីការ $(E)$ គឺ $y=Ae^{-x}+Be^{3x}$

គ . ផ្ទៀងផ្ទាត់ថា $y=y_p+y_c$ ជាចម្លើយទូទៅនៃសមីការ$(E)$

ដោយ $y=Ae^{-x}+Be^{3x}-2x^2+3x-\dfrac{10}{3}$ នោះគេបាន

$$y'=-Ae^{-x}+3Be^{3x}-4x+3$$

$$y''=Ae^{-x}+9Be^{3x}-4$$

$$y''-2y'-3y=Ae^{-x}+9Be^{3x}-4+2Ae^{-x}-6Be^{3x}+8x-6-3Ae^{-x}-3Be^{3x}+6x^2-9x+10$$

$y''-2y'-3y=6x^2-x$ ផ្ទៀងផ្ទាត់

ដូចនេះ ចម្លើយទូទៅនៃសមីការ$(E)$ គឺ $y=Ae^{-x}+Be^{3x}-2x^2+3x-\dfrac{10}{3}$

**ប្រតិបត្តិ** :គេឱ្យសមីការឌីផេរ៉ង់ស្យែល $y''+4y'+4y=-4x \qquad (E)$

ក . រកចម្លើយពិសេសនៃសមីការ$(E)$ ។

ខ . ដោះស្រាយសមីការ $(E)$ តាមលក្ខខណ្ឌដើម $y(0)=2$ , $y'(0)=-2$ ។

**លំហាត់គំរូទី ៨** : បើគេព្យួរវត្ថុមានម៉ាស $m=1kg$ នៅចុងនៃរ៉ឺសរមួយ រ៉ឺសរលូតបានប្រវែង $0.20m$ ។ក្នុងខណៈ $t=0$ គេឱ្យវត្ថុបិតនៅខាងក្រោមទីតាំងលំនឹងចម្ងាយ $0.40m$ ។ បន្ទាប់មកគេលែងវត្ថុឱ្យរត់ឡើងលើដោយល្បឿន $0.70m/s$ ។

រកសមីការនៃចលនាសេរីនេះ ។

ចម្លើយ

ដោយ ម៉ាស $m=1kg$ ធ្វើឱ្យរ៉ឺសរលូតបាន ប្រវែង $0.20m$

នោះតាមច្បាប់ហ៊ុក គេបាន

$$mg=kS\Rightarrow k=\frac{mg}{S}=\frac{1\times 9.8}{0.20}=49N/m$$

ដោយចលនានេះគ្មានកម្លាំងកកិត នោះគេបានសមីការ

$$\frac{d^2x}{dt^2}+\frac{k}{m}x=0$$

$$\frac{d^2x}{dt^2}+\frac{49}{1}x=0$$

ឬ $\quad x''+49=0$

គេដឹងថាក្នុងខណៈ $t=0$ , $x=0.40m$ នោះគេបាន $x(0)=0.4$ ហើយល្បឿននៅខណៈពេល $t=0$ គឺ $0.70m/s$ នោះគេបាន $x'(0)=-0.7$

ដោះស្រាយសមីការ $x''+49=0$ តាមលក្ខខណ្ឌដើម $x(0)=0.4$ និង $x'(0)=-0.7$

សមីការសម្គាល់នៃ $x''+49=0$ គឺ $\lambda^2+49=0$

យើងប្រើម៉ាស៊ីនគិតលេខ $fx$ 991 Plus ES ដើម្បីដោះស្រាយ

ចូលការដោះស្រាយសមីការដឺក្រេទី ២ [MODE] [5] [3]

បញ្ចូលតម្លៃមេគុណ [1] [=] [0] [=] [4] [9] [=] [=]

គេបាន $\lambda_1=-7i$ និង [▼] $\lambda_2=7i$

នោះចម្លើយទូទៅនៃ សមីការ $x''+49=0$ គឺ $x(t)=A\cos 7t+\sin 7t$

$$x'(t)=-7A\sin 7t+7\cos 7t$$

តាមលក្ខខណ្ឌដើម $x(0)=0.4$ គេបាន $0.4=A$ ឬ $A=\frac{2}{5}$

$x'(0)=-0.7$ គេបាន $-0.7=7B$ ឬ $B=-\frac{1}{10}$

ដូចនេះសមីការនៃចលនាសេរី គឺ $x(t)=\frac{2}{5}\cos 7t-\frac{1}{10}\sin 7t$

**ប្រតិបត្តិ** : វត្ថុមួយមានម៉ាស $m=0.75kg$ ត្រូវបានគេព្យួរនៅចុងនៃរ៉ឺសរមួយ ក្នុងមជ្ឈដ្ឋានមួយដែលមានសំទុះទំនាញផែនដី $9.6m/s^2$ ពេលនោះរ៉ឺសរលូតបាន ប្រវែង $0.1m$ ។ សរសេរសមីការនៃចលនារបស់វត្ថុ បើវត្ថុនោះត្រូវគេលែងចេញពីទីតាំងមួយនៅខាងលើទីតាំងលំនឹងចម្ងាយ $0.25m$ ។

**លំហាត់គំរូទី ៩** : បើគេព្យួរវត្ថុមានម៉ាស $m=0.25kg$ នៅចុងនៃរ៉ឺសរមួយ គេឃើញ រ៉ឺសរលូតបាន ប្រវែង $61cm$ ។ក្នុងតាំងលំនឹងគេប្រើកម្លាំងឱ្យម៉ាសរត់ទៅលើដោយល្បឿនដើម $0.9m/s$ ចម្ងាយ $0.40m$ ។គេសន្មតថាប្រព័ន្ធចលនាមានកម្លាំងកកិតពីរដងនៃល្បឿនដែលកំពុងមានក្នុងចលនា និង $g=9.76m/s^2$ ។

រកសមីការនៃបម្លាស់ទី $x(t)$ ។




## ចម្លើយ

រកសមីការនៃបម្លាស់ទី $x(t)$

តាមច្បាប់ហ៊ុក គេបាន

$$mg=kS\Rightarrow k=\frac{mg}{S}=\frac{0.25\times 9.76}{0.61}$$

យើងប្រើម៉ាស៊ីនគិតលេខ $fx$ 350 ES ដើម្បីដោះស្រាយ

ចូលការគណនាទូទៅ [MODE] [1]

បញ្ចូលតម្លៃ [▭/▭] [0] [.] [2] [5] [×] [9] [.] [7] [6] [▶] [0] [.] [6] [1] [=] $k=4N/m$

សមីការឌីផេរ៉ង់ស្យែលនៃចលនានេះគឺ

$$0.25\frac{d^2x}{dt^2} = -4x - 2\frac{dx}{dt}$$

$$x'' + 8x' + 16x = 0$$

ដែលមានលក្ខខណ្ឌដើម $x(0) = 0$ ; $x'(0) = -0.9$

គេបានសមីការសម្គាល់នៃសមីការ $x'' + 8x' + 16x = 0$ គឺ $\lambda^2 + 8\lambda + 16 = 0$

យើងប្រើម៉ាស៊ីនគិតលេខ $fx$ 991 ES ដើម្បីដោះស្រាយ




ចូលការដោះស្រាយសមីការដឺក្រេទី ២ MODE 5 3

បញ្ចូលតម្លៃមេគុណ 1 = 8 = 1 6 = =

គេបាន $\lambda_1 = \lambda_2 = -4$

នោះចម្លើយទូទៅនៃ សមីការ $x'' + 8x' + 16x = 0$ គឺ

$$x(t) = Ae^{-4t} + Bte^{-4t}$$

$$x'(t) = -4Ae^{-4t} + Be^{-4t} - 4Bte^{-4t}$$

តាមលក្ខខណ្ឌដើម $x(0) = 0$ ; $x'(0) = -0.9$

គេបាន $A = 0$ និង $-4A + B = -0.9 \Rightarrow B = -0.9$

ដូចនេះ $x(t) = -0.9te^{-4t}$

ប្រតិបត្តិ : គេព្យួរម៉ាស $m = 0.5kg$ នៅចុងនៃរ៉ឺសរមួយមានប្រវែង $0.82m$ ។ គេរុញម៉ាសទៅលើឃ្លាតពីទីតាំងលំនឹង $0.2m$ រួចគេលែងឱ្យម៉ាស់មានចលនា។ ប្រព័ន្ធចលនានេះឋិតក្នុងមជ្ឈដ្ឋានមានកម្លាំងកកិតស្មើនឹងល្បឿនដែលកំពុងចលនាក្នុង ( ក្នុងទឹក ) ។ រកសមីការនៃបម្លាស់ទី $x'(t)$ ។

## លំហាត់

១ . ដោះស្រាយសមីការឌីផេរ៉ង់ស្យែល :

ក . $2y''-3y'+y=0$ ខ . $-4y''+7y'+2y=0$

គ . $y''-2y'=0$ ឃ . $2y''+3y'-2y=0$

ង . $y''-3y'+3y=0$ ច . $y''-3y'+y=0$

២ . ដោះស្រាយសមីការឌីផេរ៉ង់ស្យែលមានលក្ខខណ្ឌដើម

ក . $y''-y=0$ ; $y(0)=1$ , $y'(0)=-2$

ខ . $y''-2y'+3y=0$ ; $y(0)=2$ , $y'(0)=1$

គ . $y''+y=0$ ; $y\left(\frac{\pi}{2}\right)=3$ , $y'\left(\frac{\pi}{2}\right)=-2$

ឃ . $y''-3y'+3y=0$ ; $y(1)=1$ , $y'(1)=3$

៣ . គេមានសមីការឌីផេរ៉ង់ស្យែល $y''-4y'+2y=4 \quad (E)$

ក . រកអនុគមន៍ថេរ $k$ ដែលជាចម្លើយពិសេសនៃ $(E)$ ។

ខ . ដោះស្រាយសមីការ $y''-4y'+2y=4$

គ . រកចម្លើយពិសេសនៃ $(E)$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌដើម $y(0)=2\sqrt{2}$ , $y'(0)=0$

៤ . គេមានសមីការឌីផេរ៉ង់ស្យែល $y''+3y'=5 \quad (E)$

ក . រកឫសនៃសមីការសម្គាល់នៃសមីការ $(E)$

ខ . រកអនុគមន៍ $g(x)=Ax$ ដែលជាចម្លើយពិសេសនៃ $(E)$ ។

គ . ដោះស្រាយសមីការ $y''+3y'=5$

ឃ . រកចម្លើយដោយឡែកនៃ $(E)$ កាលណា $y(0)=e^3$ , $y'(1)=\frac{2}{3}$

# ជំពូក ៥ បំណែងចែកប្រូបាប

## មេរៀនទី ១ បំណែងចែកប្រូបាប

### មេរៀនសង្ខេប

-បើ $x$ ជាអនុគមន៍ថេរចៃដន្យដាច់និង $p_1+p_2+.....+p_n=1$ នោះគេអាចសរសេរ

$\sum_{i=1}^{n} p_i=1$ ឬ $\sum_{i=1}^{n} P(X=x)=1$ ។

-អនុគមន៍ដែលអាចគណនាតម្លៃ $P(X=x)$ ចំពោះគ្រប់ $x$ ទាំងអស់ហៅថាអនុគមន៍ដង់ស៊ីតេប្រូបាបនៃអថេរចៃដន្យដាច់ $x$ ។

-សង្ឃឹមគណិតនៃអថេរ $X$ ដែលតាងដោយ $E(X)$ ឱ្យដោយរូបមន្ត

$E(X)=\sum_{i=1}^{n} x\times P(X=x)$ ឬសរសេរ $E(X)\sum_{i=1}^{n} x_i p_i$ ។

-បើ $f(x)$ ជាអនុគមន៍នៃអថេរចៃដន្យដាច់ $X$ នោះ $E\left[f(X)\right]=\sum_{i=1}^{n}\left[f(x)\times P(X=x)\right]$

-លក្ខណៈនៃសង្ឃឹមគណិត

បើ $X$ ជាអថេរចៃដន្យដាច់ ហើយ $a$ និង $b$ ជាចំនួនថេរ នោះគេបាន :

១. $E(a)=a$

២. $E(aX)=aE(X)$

៣. $E(aX+b)=aE(x)+b$ .

- វ៉ារ្យង់នៃអថេរចៃដន្យដាច់ $X$ តាងដោយ $Var(X)$ កំណត់ដោយ $Var(X)=E(X-\mu)^2$

ដែល $\mu=E(X)$ ។

$\delta=\sqrt{Var(x)}$ ហៅថាគំលាតស្តង់ដា

- លក្ខណៈនៃវ៉ារ្យង់

បើ $X$ ជាអថេរចៃដន្យដាច់ហើយ $a$ និង $b$ ជាចំនួនថេរ នោះគេបាន :

១ . $Var(a)=0$

២ . $Var(X)=a^2Var(X)$

៣. $Var(aX+b)=a^2Var(X)$

**លំហាត់គំរូទី ១:** គេបោះគ្រាប់ឡុកឡាក់បីគ្រាប់ព្រមគ្នា។ $X$ ជាអថេរចៃដន្យដែល ជា ( ចំនួនលេខ 3 ដែលមាននៅក្នុងលទ្ធផលនីមួយៗ ) គណនាប្រូបាប $P(X=x)$ រួចធ្វើតារាងបំណែងចែកប្រូបាបនៃ $X$ ។

## ចម្លើយ

តាង $a$ ជាលេខផ្សេងពីលេខ 3 ។

នោះលទ្ធផលនៃការបោះគ្រាប់ឡុកឡាក់មាន : $aaa$ , $3aa$ , $a3a$ , $33a$ , $3a3$ , $a33$, $333$

ដោយព្រឹត្តិការណ៍មិនទាក់ទងគ្នា គេបាន :

$$P(X=0)=P(aaa)=P(a)\times P(a)\times P(a)=\frac{5}{6}\times\frac{5}{6}\times\frac{5}{6}=\frac{125}{216}$$

$$P(X=1)=P(3aa)+P(a3a)\times P(aa3)=3\left(\frac{1}{6}\times\frac{5}{6}\times\frac{5}{6}\right)=\frac{75}{216}$$

$$P(X=2)=P(33a)\times P(3a3)\times P(a33)=3\left(\frac{1}{6}\times\frac{5}{6}\times\frac{5}{6}\right)=\frac{75}{216}$$

$$P(X=3)=P(333)=P(3)\times P(3)\times P(3)=\frac{1}{6}\times\frac{1}{6}\times\frac{1}{6}=\frac{1}{216}$$

ដូចនេះ តារាងបំណែងចែកប្រូបាបនៃ $X$ គឺ

| $x$ | 0 | 1 | 2 | 3 |
|---|---|---|---|---|
| $P(X=x)$ | $\frac{125}{216}$ | $\frac{75}{216}$ | $\frac{15}{216}$ | $\frac{1}{216}$ |

**លំហាត់គំរូទី ២** :គេមានបំណែងចែកប្រូបាបនៃអថេរចៃដន្យ $X$ ដូចបង្ហាញក្នុងតារាងខាងក្រោម:

| $x$ | 0 | 1 | 2 | 3 | 4 |
|---|---|---|---|---|---|
| $P(X=x)$ | 0.1 | 0.3 | c | 0.2 | 0.1 |

ក . គណនាតម្លៃ c ខ . គណនា $P(2\le X\le 4)$ គ. គណនា $P(X<3)$

## ចម្លើយ




ក . គណនាតម្លៃ c

តាមតារាង គេបាន $P(0)+P(1)+P(2)+P(3)+P(4)=1$

$$0.1+0.3+c+0.2+0.1=1$$

$$c=1-0.7=0.3$$

តាម ម៉ាស៊ីនគិតលេខ $fx$ 350 ES

ចុច [MODE] [1]

គណនា [1] [−] [0] [.] [1] [−] [0] [.] [3] [−] [0] [.] [2] [−] [0] [.] [1] [=] $c=0.3$

ខ . គណនា $P(2\le X\le 4)$

$$P(2\le X\le 4)=P(2)+P(3)+P(4)$$
$$=0.3+0.2+0.1$$
$$=0.6$$

តាម ម៉ាស៊ីនគិតលេខ $fx$ 350 ES

ចុច [MODE] [1]

គណនា [0] [·] [3] [+] [0] [·] [2] [+] [0] [·] [1] [=] $P(2\le X\le 4)=0.6$

គ. គណនា $P(X<3)$

$$P(X<3)=P(0)+P(1)+P(2)$$
$$=0.1+0.3+0.3$$
$$=0.7$$

តាម ម៉ាស៊ីនគិតលេខ $fx$ 350 ES

ចុច [MODE] [1]

គណនា [0] [·] [1] [+] [0] [·] [3] [+] [0] [·] [3] [=] $P(X<3)=0.7$

**លំហាត់គំរូទី ៣:** អនុគមន៍ដង់ស៊ីតេប្រូបាបនៃអថេរដាច់ $Y$ កំណត់ដោយ $P(Y=y)=cy^2$ ចំពោះគ្រប់ $y=0,1,2,3,4$ ហើយ $c$ ជាចំនួនថេរ ។

ក . គណនា $P(Y=y)$ ចំពោះតម្លៃនីមួយៗនៃ $y$ រួចធ្វើតារាងបំណែងចែកប្រូបាបនៃ $Y$ ។

ខ . គណនា តម្លៃ $c$ ។

## ចម្លើយ

ក . គណនា $P(Y=y)$

បើ $y=0$ នោះ $P(Y=0)=0$

បើ $y=1$ នោះ $P(Y=1)=c$

បើ $y=2$ នោះ $P(Y=2)=4c$

បើ $y=3$ នោះ $P(Y=3)=9c$

បើ $y=4$ នោះ $P(Y=4)=16c$

ដូចនេះ តារាងបំណែងចែកប្រូបាបនៃ $Y$ គឺ

| $y$ | 0 | 1 | 2 | 3 | 4 |
|---|---|---|---|---|---|
| $P(Y=y)$ | 0 | c | 4c | 9c | 16c |

ខ . គណនា តម្លៃ $c$

ដោយ $Y$ ជាអថេរចៃដន្យនោះគ្រប់តម្លៃ $y$ គេបាន

$$\sum_{i=0}^{4}P(Y=y)=1$$
$$c+4c+9c+16c=1$$
$$c=\frac{1}{30}$$

**ប្រតិបត្តិ** : អថេរចៃដន្យដាច់ $R$ មានអនុគមន៍ដង់ស៊ីតេប្រូបាបកំណត់ដោយ

$$P(R=r)=c(3-r) \quad \text{ចំពោះគ្រប់ } r=0\,,1\,,2\,,3 \quad ។$$

ក . គណនា $P(R=r)$ រួចធ្វើតារាងបំណែងចែកប្រូបាប ។

ខ . គណនា តម្លៃ $c$ ។

គ . គូសក្រាបអង្កត់ឈរតាងបំណែងចែកប្រូបាប ។

**លំហាត់គំរូទី ៤** : នៅក្នុងឆ្នាំនេះប្រូបាបដែលតម្លៃផ្ទះនឹងឡើងថ្លៃ 20% ស្មើនឹង 0.3 ប្រូបាបដែលតម្លៃផ្ទះនឹងឡើងថ្លៃ 10% ស្មើនឹង 0.5 ហើយ ប្រូបាបដែលតម្លៃផ្ទះនឹងចុះថ្លៃ10% ស្មើនឹង 0.1 ។ តើអ្នកសង្ឃឹមថាផ្ទះនឹងឡើងថ្លៃប៉ុន្មានភាគរយ ?




## ចម្លើយ

តាង $X$ ជាអថេរ “ តម្លៃផ្ទះនឹងឡើងថ្លៃគិតភាគរយ “

គេបានតារាងបំណែងចែកប្រូបាបនៃ $X$ គឺ

| $x$ | 20% | 10% | -10% |
|---|---|---|---|
| $P(X=x)$ | 0.3 | 0.5 | 0.1 |

តាមរូបមន្ត $E(X)=\sum\left[x\times P(X=x)\right]$

$$=20\%\times 0.3+10\%\times 0.5-10\%\times 0.1$$

តាម ម៉ាស៊ីនគិតលេខ *fx*- 350 ES

ចុច [MODE] [1]

គណនា [2] [0] [SHIFT] [(] [×] [0] [·] [3] [+] [1] [0] [SHIFT] [(] [×] [0] [·] [5]

[−] [1] [0] [SHIFT] [(] [×] [0] [·] [1] [=] $E(X)=0.1=10\%$

ដូចនេះ យើងសង្ឃឹមទុកថា តម្លៃផ្ទះនឹងឡើងថ្លៃ 10%

**ប្រតិបត្តិ** : តារាងបំណែងចែកប្រូបាបខាងក្រោមបង្ហាញពីរង្វាន់លើកទឹកប្រាក់នៃឆ្នោតកោសនៅកន្លែងមួយ ។ បើអ្នកទិញឆ្នោតមួយសន្លឹក គណនាប្រូបាបដែលនឹងឈ្នះឆ្នោត :

| រង្វាន់ ( ពាន់រៀល) | 0 | 10 | 100 | 500 |
|---|---|---|---|---|
| ប្រូបាប | 0.45 | 0.30 | 0.20 | 0.05 |

ក . 100 ពាន់រៀល

ខ . យ៉ាងតិច 10 ពាន់រៀល

គ . មិនលើសពី 100 ពាន់រៀល

ឃ . តើអ្នកសង្ឃឹមឈ្នះឆ្នោតប៉ុន្មានពាន់រៀល ?

**លំហាត់គំរូទី ៥** : $X$ ជាអថេរចៃដន្យ ដែលមានអនុគមន៍ដង់ស៊ីតេប្រូបាប $P(X=x)$ ចំពោះ $x=1\,,2\,,3$ ។

| $x$ | 1 | 2 | 3 |
|---|---|---|---|
| $P(X=x)$ | 0.1 | 0.6 | 0.3 |

គណនា ក . $E(5X)$ ខ . $E(X^2)$ គ. $E(5X+3)$




## ចម្លើយ

គណនា ក . $E(5X)$

តាមរូបមន្ត $E(5X)=\sum\left[5x\times P(X=x)\right]$

$$=5\times1\times0.1+5\times2\times0.6+5\times3\times0.3$$

តាម ម៉ាស៊ីនគិតលេខ *fx* 350 ES

ចុច [MODE] [1]

គណនា [5] [×] [1] [×] [0] [•] [1] [+] [5] [×] [2] [×] [0] [•] [6] [+] [5] [×] [3] [×] [0] [•] [3] [=] $E(5X)=11$

ខ . $E(X^2)$

តាមរូបមន្ត $E(X^2)=\sum\left[x^2\times P(X=x)\right]$

$$=1^2\times0.1+2^2\times0.6+3^2\times0.3$$

តាម ម៉ាស៊ីនគិតលេខ *fx* 350 ES

ចុច [MODE] [1]

គណនា [1] [$x^2$] [×] [0] [•] [1] [+] [2] [$x^2$] [×] [0] [•] [6] [+] [3] [$x^2$] [×] [0] [•] [3] [=] [S⇔D] $E(X^2)=\frac{26}{5}=5.2$

គ. $E(5X+3)$

តាមរូបមន្ត $E(5X+3)=\sum\left[(5x+3)\times P(X=x)\right]$

$$=(5\times1+3)\times0.1+(5\times2+3)\times0.6+(5\times3+3)\times0.3$$

តាម ម៉ាស៊ីនគិតលេខ *fx* 350 ES

ចុច [MODE] [1]

គណនា [(] [5] [×] [1] [+] [3] [)] [×] [0] [•] [1] [+] [(] [5] [×] [2] [+] [3] [)] [×] [0] [•] [6] [+] [(] [5] [×] [3] [+] [3] [)] [×] [0] [•] [3] [)] [=] $E(5X+3)=14$

**លំហាត់គំរូទី ៦** : $X$ ជាអថេរចៃដន្យដាច់ ដែលមានអនុគមន៍ដង់ស៊ីតេប្រូបាប $P(X=x)$ ចំពោះ $x=1,2,3$ ។




| $x$ | 1 | 2 | 3 |
|---|---|---|---|
| $P(X=x)$ | 0.2 | 0.3 | 0.5 |

គណនា ក . $5E(X)+2$ ខ . $E(X^2+4)$

**ចម្លើយ**

គណនា ក . $5E(X)+2$

តាមរូបមន្ត $5E(X)+2=5\sum\left[x\times P(X=x)\right]+2$

$=5(1\times 0.2+2\times 0.3+3\times 0.5)+2$

តាម ម៉ាស៊ីនគិតលេខ *fx* 350 ES

ចុច [MODE] [1]

គណនា [5] [×] [(] [1] [×] [0] [.] [2] [+] [2] [×] [0] [.] [3]

[+] [3] [×] [0] [.] [5] [)] [+] [2] [=] [S⇔D] $5E(X)+2=\frac{26}{2}=13.5$

ខ . $E(X^2+4)$

តាមរូបមន្ត
$E(X^2+4)=E(X^2)+E(4)$

$=\sum\left[x^2\times P(X=x)\right]+4$

$=(1^2\times 0.2+2^2\times 0.3+3^2\times 0.5)+4$

តាម ម៉ាស៊ីនគិតលេខ *fx* 350 ES

ចុច [MODE] [1]

គណនា [(] [1] [x²] [×] [0] [.] [2] [+] [2] [x²] [×] [0]

[.] [3] [+] [3] [x²] [×] [0] [.] [5] [)] [+] [4] [=] [S⇔D] $E(X^2+4)=\frac{99}{10}=9.9$

**ប្រតិបត្តិ** : $X$ ជាអថេរចៃដន្យដាច់ ដែលមានអនុគមន៍ដង់ស៊ីតេប្រូបាប $P(X=0)=0.05$ $P(X=1)=0.45$ , $P(X=2)=0.5$ ។ គណនា

ក . $\mu=E(X)$ ខ . $E(X^2)$ គ . $E(5X^2+2X-3)$

**លំហាត់គំរូទី ៧**:អថេរចៃដន្យដាច់ $X$ ដែលមានបំណែងចែកប្រូបាបដូចតារាងខាងក្រោម

| $x$ | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|
| $P(X=x)$ | 0.1 | 0.3 | 0.2 | 0.3 | 0.1 |

គណនា ក . $Var(X)$ ដោយប្រើរូបមន្ត $Var(X)=E(X-\mu)^2$

ខ . $Var(X)$ ដោយប្រើរូបមន្ត $Var(X)=E(X^2)-E^2(X)$

# ចម្លើយ

ក . គណនា $Var(X)$ ដោយប្រើរូបមន្ត $Var(X)=E(X-\mu)^2$

ដំបូងត្រូវរក $\mu$

គេបាន $\mu=E(X)=\sum[x\times P(X=x)]$

$=1(0.1)+2(0.3)+3(0.2)+4(0.3)+5(0.1)$

$=3$

គេបាន $Var(X)=E(X-3)^2$

$=\sum\left[(x-3)^2\times P(X=x)\right]$

$=4(0.1)+1(0.3)+0(0.2)+1(0.3)+4(0.1)$

$=1.4$

ដូចនេះ $Var(X)=1.4$

ខ . គណនា $Var(X)$ ដោយប្រើរូបមន្ត $Var(X)=E(X^2)-E^2(X)$

$E(X^2)=\sum[x^2\times P(X=x)]$

$=1(0.1)+4(0.3)+9(0.2)+16(0.3)+25(0.1)$

$=10.4$

គេបាន $Var(X)=E(X^2)-\mu^2=10.4-3^2=1.4$

ដូចនេះ $Var(X)=1.4$

**លំហាត់គំរូទី ៨** : $X$ ជាអថេរចៃដន្យដែលមានបំណែងចែកប្រូបាបដូចតារាងខាងក្រោម

| $x$ | 10 | 20 | 30 |
|---|---|---|---|
| $P(X=x)$ | 0.1 | 0.6 | 0.3 |

គណនា $Var(2X+3)$

# ចម្លើយ

គណនា $Var(2X+3)$

គេបាន $Var(2X+3)=2^2Var(X)=4Var(X)$ (1)

$Var(X)=E(X^2)-E^2(X)$

$E(X)=\sum[x\times P(X=x)]=10(0.1)+20(0.6)+30(0.3)=22$

$E(X^2)=\sum[x^2\times P(X=x)]=100(0.1)+400(0.6)+900(0.3)=520$

នាំឱ្យ $Var(X)=520-22^2=36$

តាម គេបាន $Var(2X+3)=4\times 36=144$

ដូចនេះ $Var(2X+3)=144$

## លំហាត់

១ . អថេរចៃដន្យដាច់ $X$ មានអនុគមន៍ដង់ស៊ីតេប្រូបាប ដូចបង្ហាញតាមតារាងខាងក្រោម :

| $x$ | -3 | -2 | -1 | 0 | 1 |
|---|---|---|---|---|---|
| $P(X=x)$ | 0.1 | 0.25 | 0.3 | 0.15 | d |

គណនា ក . តម្លៃ d ខ . $P(-3\le X<0)$ គ. $P(X>-1)$

ឃ . $P(-1<X<1)$ ង . ម៉ូត ។

២ . អថេរចៃដន្យដាច់ $X$ មានអនុគមន៍ដង់ស៊ីតេប្រូបាប $P(X=x)$ ចំពោះ $x=5,6,7,8,9$ ដែល កំណត់ដូចតារាងខាងក្រោម :

| $x$ | 5 | 6 | 7 | 8 | 9 |
|---|---|---|---|---|---|
| $P(X=x)$ | $\frac{3}{11}$ | $\frac{2}{11}$ | $\frac{1}{11}$ | $\frac{2}{11}$ | $\frac{3}{11}$ |

គណនា $\mu$ ។

៣ . អថេរចៃដន្យដាច់ $X$ មានអនុគមន៍ដង់ស៊ីតេប្រូបាប $P(X=x)$ ចំពោះ $x=1$ , 2 , 3 ដែល កំណត់ដូចតារាងខាងក្រោម :

| $x$ | 1 | 2 | 3 |
|---|---|---|---|
| $P(X=x)$ | 0.1 | 0.4 | 0.5 |

គណនា ក . $E(X)$ ខ . $E(X^2)$ គ . $E(2X^2+2X-5)$ ឃ . $Var(X)$

៤ . បើ $X$ ជាអថេរចៃដន្យដាច់(ពិន្ទុដែលចេញពេលគេបោះគ្រាប់ឡុកឡាក់)ហើយអនុគមន៍ដង់ស៊ីតេប្រូបាបឱ្យដោយតារាងខាងក្រោម :

| $x$ | 1 | 2 | 3 | 4 | 5 | 6 |
|---|---|---|---|---|---|---|
| $P(X=x)$ | $\frac{1}{6}$ | $\frac{1}{6}$ | $\frac{1}{5}$ | y | $\frac{1}{5}$ | $\frac{1}{6}$ |

គណនា ក . $y$ ខ . $E(X)$ គ . $E(X^2)$ ឃ . $Var(X)$ ង . $Var(4X)$

៥ . តារាងបំណែងចែកប្រូបាបខាងក្រោមបង្ហាញពីចំនួនគ្រោះថ្នាក់ចរាចរណ៍ប្រចាំថ្ងៃ :

| $x$ | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|
| $P(X=x)$ | 0,20 | 0,40 | 0,20 | 0,15 | 0,05 |

គណនា ក . ចំនួនគ្រោះថ្នាក់ចរាចរណ៍ ដែលសង្ឃឹមទុកក្នុងមួយថ្ងៃ ។

ខ . វ៉ារ្យង់ ។

៦ . គណនាចំនួនដងដែលសង្ឃឹមទុកថានឹងផ្ងារឡើងបានខាងរូបក្បាល កាលណាគេបោះកាក់ពីរព្រមគ្នា ។

៧ . តារាងបំណែងចែកប្រូបាបខាងក្រោមបង្ហាញពីចំនួនគ្រោះថ្នាក់ចរាចរណ៍ប្រចាំខែ :

| $x$ | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|
| $P(X=x)$ | 0.20 | 0.40 | 0.20 | 0.15 | 0.05 |

ក . គណនាចំនួនគ្រោះថ្នាក់ចរាចរណ៍ ដែលសង្ឃឹមទុកក្នុង ១ ថ្ងៃ ។

ខ . គណនា វ៉ារ្យង់ ។

មេរៀនទី

២

# បំណែងចែកទ្វេធា

## មេរៀនសង្ខេប

-ក្នុងការពិសោធមួយដែលមាន $n$ វិញ្ញាសា បើប្រូបាបដែលទទួលបានជោគជ័យស្មើនឹង $p$ ប្រូបាបដែលបរាជ័យស្មើនឹង $q=1-p$ និង $X$ ជាអថេរចៃដន្យទ្វេធា នោះអនុគមន៍ដង់ស៊ីតេប្រូបាបនៃអថេរ $X$ កំណត់ដោយ $P(X=x)=C(n,x)\times p^{x}(1-p)^{n-x}$ ដែល $x=0,1,2,3,\ldots,n$ ។

-បើ $X$ ជាអថេរចៃដន្យទ្វេធានៃបំណែងចែកទ្វេធា គេកំណត់សរសេរ $X\sim Bin(n,p)$ ដែល $n$ ជាចំនួនដងនៃការពិសោធមិនទាក់ទងគ្នា ហើយ $p$ ជាប្រូបាបដែលទទួលបានជោគជ័យក្នុងការពិសោធម្តង ។

-បើ $X$ ជាអថេរចៃដន្យនៃ $Bin(n,p)$ នោះ $E(X)=np$ ហើយ $Var(x)=np(1-p)$ ។

-ដើម្បីរកតម្លៃនៃ $X$ ដែលធ្វើឱ្យមានតម្លៃប្រូបាបធំជាងគេ គេត្រូវរកតម្លៃនៃ $X$ ដែលនៅជុំវិញតម្លៃមធ្យម ឬ $E(X)$ ។

**លំហាត់គំរូទី ១**: គេដឹងថាប្រូបាបដែលសិស្សម្នាក់ប្រលងជាប់តែសគណិតវិទ្យាស្មើនឹង 0.75 ។គណនាប្រូបាបដែលសិស្សមួយក្រុមមានគ្នា 10 នាក់ប្រលងជាប់តែសគណិត-វិទ្យាលើសពី 5 នាក់ ។

## ចម្លើយ

